ក្រសួងមហាផ្ទៃ

# សៀវភៅណែនាំសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់
# ស្តីពី



## ការលើកកម្ពស់ដល់ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់

៣.ស.២៥៦៧

អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ
ឧបត្ថម្ភបោះពុម្ពដោយយូនីសេហ្វ

ឆ្នាំ២០២៣

# អារម្ភកថា

តាមទិន្នន័យជំរឿនទូទៅប្រជាជននៅឆ្នាំ២០១៩ ប្រទេសកម្ពុជាមានយុវជន(យុវជននិងយុវតី) អាយុក្រោម៣០ឆ្នាំប្រមាណ៥៧ភាគរយ។ បើធៀបនឹងបណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ ប្រទេសកម្ពុជាមានចំនួនយុវជនធៀបនឹងប្រជាជនសរុបធំជាងគេ។ តួលេខនេះបង្ហាញថាយុវជន គឺជាធនធានដែលមានសក្តានុពលនៅក្នុងការបន្តនិរន្តរភាព និងអភិវឌ្ឍសង្គម សេដ្ឋកិច្ច វប្បធម៌ បរិស្ថាន និងការរក្សាសន្តិភាពទាំងនៅពេលបច្ចុប្បន្ននិងអនាគតសម្រាប់ប្រទេសកម្ពុជា។

ដោយមើលឃើញពីសក្តានុពលរបស់យុវជន និងដើម្បីលើកកម្ពស់យុវជនកម្ពុជាក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជានៅឆ្នាំ២០១១។ គោលនយោបាយជាតិនេះបានដាក់ចេញនូវយុទ្ធសាស្ត្រជាច្រើន ដើម្បីលើកកម្ពស់និងគាំទ្រដល់យុវជនកម្ពុជា ជាពិសេសយុទ្ធសាស្ត្របង្កើនការចូលរួមរបស់យុវជនដែលរួមមាន៖១)-បង្កលក្ខណៈងាយស្រួលឱ្យយុវជនចូលរួមបានពេញលេញក្នុងសហគមន៍មូលដ្ឋាននិងស្ថាប័ននានា ២)-ជំរុញយន្តការជាផ្លូវការឱ្យយុវជនចូលរួមប្រកបដោយប្រសិទ្ធភាពជាមួយនឹងសមាគម អង្គការមិនមែនរដ្ឋាភិបាល ឬអង្គការសង្គមស៊ីវិល ៣)-ជំរុញឱ្យមានតំណាងយុវជននៅក្នុងគណៈកម្មាធិការឬក្រុមប្រឹក្សាថ្នាក់ជាតិឬថ្នាក់ក្រោមជាតិ និងធានាការធ្វើសមាហរណកម្មពួកគេទៅក្នុងដំណើរការរៀបចំផែនការនិងសៃវាហមជ្ឈការ ៤)-គាំទ្រឱ្យមានសំឡេងយុវជននៅក្នុងដំណើរការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាដែលជាផលប្រយោជន៍របស់យុវជន។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តកន្លងទៅនេះ យើងបានសង្កេតឃើញថាការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍមូលដ្ឋាននៅមានកម្រិតនៅឡើយ ជាពិសេសការចូលរួមរបស់យុវជនក្នុងការរៀបចំនិងការសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់។ ផ្អែកលើមូលដ្ឋាននេះ ក្រុមការងារអគ្គនាយកដ្ឋានរដ្ឋបាល តាមរយៈគម្រោងលើកកម្ពស់វិស័យសេវាសង្គមដែលគាំទ្រដោយយូនីសេហ្វ បានសិក្សាលើឯកសារបច្ចេកទេសដែលកំពុងអនុវត្ត និងបានដកស្រង់បទពិសោធពាក់ព័ន្ធនឹងការចូលរួមរបស់យុវជនក្នុងការងារអភិវឌ្ឍនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយបានរៀបចំសៀវភៅណែនាំសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ស្តីពីការលើកកម្ពស់ដល់ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់។

សៀវភៅណែនាំនេះជាឯកសារជំនួយស្មារតីសម្រាប់ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យយកចិត្តទុកដាក់គិតគូរបន្ថែមទៀតចំពោះយុវជនកម្ពុជា ដើម្បីលើកកម្ពស់និងជំរុញយុវជនឱ្យចូលរួមអភិវឌ្ឍឃុំ សង្កាត់ តាមរយៈដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់។ ខ្លឹមសារនៃសៀវភៅណែនាំនេះមានលក្ខណៈសង្ខេបដែលបានផ្តោតតែទៅលើយុវជននិងយុវតីជាមួយនឹងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់ប៉ុណ្ណោះ។ ទោះយ៉ាងណាក៏ដោយ

សៀវភៅណែនាំនេះគឺជាបច្ច័យដ៏សំខាន់មួយក្នុងការលើកកម្ពស់និងការយកចិត្តទុកដាក់ចំពោះយុវជនទាំងពីរភេទដែលជាធនធានបន្តវេន និងមានសក្តានុពលនៅក្នុងការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។

ជាមួយគ្នានេះ ក្រសួងមហាផ្ទៃសង្ឃឹមថាសៀវភៅណែនាំសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ស្តីពីការលើកកម្ពស់ដល់ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់ នឹងមានការចូលរួមយោបល់ពីអ្នកពាក់ព័ន្ធថែមទៀត ក្នុងការកែលម្អសៀវភៅណែនាំនេះឱ្យកាន់តែប្រសើរឡើងតាមពេលវេលាសមស្រប។

ថ្ងៃ.......... ខែ.......... ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.....៦..... ខែ.....តុលា.........ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

# មាតិកានុក្រម


## ផ្នែកទី១៖សេចក្តីផ្តើម ទំព័រ

១.១-សនិទានភាព ..... ៩

១.២-មូលដ្ឋានគតិយុត្តសម្រាប់រៀបចំសៀវភៅណែនាំ ..... ១០

១.៣-គោលបំណង ..... ១១

១.៤-ការប្រើប្រាស់សៀវភៅណែនាំ ..... ១២

## ផ្នែកទី២៖ទិដ្ឋភាពទូទៅនៃការចូលរួមរបស់យុវជន

២.១-វាក្យសព្ទសំខាន់ៗ ..... ១៥

២.២-អត្ថប្រយោជន៍នៃការចូលរួមរបស់យុវជន ..... ១៦

២.៣-គោលការណ៍នៃការចូលរួមរបស់យុវជន ..... ១៦

## ផ្នែកទី៣៖ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិលនិងថវិកានៃរដ្ឋបាលឃុំ សង្កាត់

៣.១-ការកំណត់ក្រុមគោលដៅយុវជនដែលត្រូវចូលរួម ..... ២០

៣.២-វិធីសាស្ត្រនៃការប្រមូលមតិនិងយោបល់របស់យុវជន ..... ២២

៣.៣-ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ..... ២៤

៣.៣.១-ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ..... ២៤

៣.៣.២-ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ២៧

៣.៤-ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ ៣០

៣.៤.១-ការផ្សព្វផ្សាយជំហានសង្ខេបស្តីពីដំណើរការរៀបចំនិងអនុម័តថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ ៣០

៣.៤.២-ការប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងគម្រោងថវិកាសង្ខេបឃុំ សង្កាត់ ៣០

៣.៤.៣-ការអនុម័តនិងការផ្សព្វផ្សាយគម្រោងថវិកាប្រចាំឆ្នាំឃុំ សង្កាត់ ៣១


## ឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១៖គោលវិធីនៃការចូលរួមរបស់យុវជន ៣៤

ឧបសម្ព័ន្ធទី២៖ក្រុមតំណាងយុវជននៅក្នុងមូលដ្ឋានឃុំ សង្កាត់ ៣៥

ឧបសម្ព័ន្ធទី៣៖សំណួរគន្លឹះសម្រាប់រៀបចំកិច្ចប្រជុំបែបយុវជនមេត្រី ៣៦

ឧបសម្ព័ន្ធទី៤៖ការស្ទង់មតិ ៣៧

ឧបសម្ព័ន្ធទី៥៖វេទិកាសំណួរចម្លើយ ៤០

ឧបសម្ព័ន្ធទី៦៖ការពិភាក្សាជាមួយនឹងក្រុមគោលដៅយុវជនជាក់លាក់ ៤១

ឧបសម្ព័ន្ធទី៧៖ទម្រង់គម្រោងថវិកាសង្ខេបឃុំ សង្កាត់ ៤៣


# ផ្នែកទី១

## សេចក្តីផ្តើម





## ១.១-សនិទានភាព

តាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឃុំ សង្កាត់នីមួយៗមានក្រុមប្រឹក្សាឃុំ សង្កាត់កើតឡើងតាមការបោះឆ្នោតផ្ទាល់ពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ រដ្ឋបាលឃុំ សង្កាត់ដឹកនាំដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានតួនាទីបម្រើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់ ហើយត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ ច្បាប់ បទបញ្ញា និងលិខិតបទដ្ឋាននានា។

រដ្ឋបាលឃុំ សង្កាត់មានតួនាទីនិងភារកិច្ចបម្រើការងារមូលដ្ឋានក្នុងកិច្ចការសេវាសាធារណៈជូនប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់ លើការងារសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ បរិស្ថាន ធនធានធម្មជាតិ និងការផ្តល់សេវាសាធារណៈនានា សំដៅជំរុញលើកកម្ពស់សុខុមាលភាពនិងជីវភាពប្រជាជនក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម នៅឃុំ សង្កាត់។ ក្នុងការអនុវត្តតួនាទីនិងភារកិច្ចទាំងនេះ រដ្ឋបាលឃុំ សង្កាត់នីមួយៗមានកាតព្វកិច្ចរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់( ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំឃុំ សង្កាត់ ) និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ព្រមទាំងរៀបចំគម្រោងថវិកាឃុំ សង្កាត់សម្រាប់ជាត្រីវិស័យក្នុងការអភិវឌ្ឍឃុំ សង្កាត់។

តាមរយៈប្រកាសរវាងក្រសួងមហាផ្ទៃនិងក្រសួងផែនការលេខ០៨០ ផ.ក លេខ០៧៤ ផ.ក និងលេខ០៧៣ ផ.ក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧ ដែលបានដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ និងប្រកាសលេខ០១៤៩ ផ.ក.ប្រក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០២០ ដែលបានដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបំពេញបន្ថែមលើសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំនិងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវរៀបចំនិងកសាងផែនការទាំងនេះឱ្យបានទាន់ពេលវេលាកំណត់និងតាមនីតិវិធីក្នុងជំហាននីមួយៗ។ ការរៀបចំផែនការនេះត្រូវមានធាតុសំខាន់ៗពាក់ព័ន្ធនឹងការប្រមូលតម្រូវការនានាពីប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធ តាមរយៈកិច្ចប្រជុំនៅតាមភូមិដែលត្រូវមានតំណាងគ្រួសាររបស់ប្រជាពលរដ្ឋចូលរួមយ៉ាងតិច៦០ភាគរយនៃគ្រួសារសរុបក្នុងភូមិនៃឃុំ សង្កាត់។ ប្រជាពលរដ្ឋសំដៅដល់កុមារ យុវជន ជនមានពិការភាព ជនជាតិដើមភាគតិច មនុស្សចាស់ និងជនងាយរងគ្រោះផ្សេងទៀតនៅក្នុងឃុំ សង្កាត់។

ទន្ទឹមនឹងគ្នានេះ តាមប្រកាសណែនាំលេខ៣៣១ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការរៀបចំនិងការអនុវត្តថវិកាឃុំ សង្កាត់ និងសេចក្តីណែនាំលេខ០២៥ ស.ណ.ន. ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំនិងការអនុម័តថវិការបស់រដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់ត្រូវរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់ជារៀងរាល់ឆ្នាំ ដោយត្រូវធានាឱ្យមានការចូលរួមពីប្រជាពលរដ្ឋឬសាធារណជននៅតាមមូលដ្ឋានឃុំ សង្កាត់។

ការចូលរួមរបស់ប្រជាពលរដ្ឋនេះជាកិច្ចការសំខាន់មួយដែលជាកត្តាជំរុញនិងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ការចូលរួមនៅក្នុងឯកសារនេះបានផ្តោតជាសំខាន់ទៅលើវត្តមានរបស់យុវជននិងយុវតីដែលហៅជារួមថាយុវជន នៅក្នុងកិច្ចអភិវឌ្ឍឃុំ សង្កាត់ «**យុវជនជាទំពាំងស្នងឫស្សី**»។ ជាក់ស្តែង រដ្ឋបាលឃុំ សង្កាត់បានយកចិត្តទុកដាក់និងលើកកម្ពស់យុវជនចូលជាសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ «**គ.ក.ន.ក.**» ដែលបានកំណត់ក្នុងសេចក្តីណែនាំលេខ០៤៥ ស.ណ.ន. ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្តីពីការជ្រើសរើសតំណាងយុវជនចូលរួមជាសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់។

ជាការណ៍ពិត វត្តមានការចូលរួមរបស់សាធារណជនមានសារៈសំខាន់ក្នុងការពិគ្រោះយោបល់ទាំងនៅតាមភូមិ និងនៅតាមសាលាឃុំ សង្កាត់ ដើម្បីលើកបញ្ហាឬតម្រូវការនានារបស់មូលដ្ឋានផ្ទាល់ដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងគម្រោងថវិកានៃរដ្ឋបាលឃុំ សង្កាត់ប្រចាំឆ្នាំ «**មានការចូលរួម មានការអភិវឌ្ឍ**»។ ក្នុងសកម្មភាពនេះដែរ វត្តមានចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍឃុំ សង្កាត់ គឺជាការរៀនសូត្រមួយសម្រាប់យុវជនក្នុងការអភិវឌ្ឍ ហើយក៏ជាកាលានុវត្តភាពក្នុងការរៀបចំខ្លួនរបស់ពួកគេមុនក្លាយជាមនុស្សពេញវ័យ និងជាប្រជាពលរដ្ឋដ៏ល្អក្នុងការបម្រើសកម្មភាពការងារសេវាសាធារណៈ នៅក្នុងសង្គមជាតិ។

ក្នុងការអនុវត្តជាក់ស្តែង ការចូលរួមរបស់យុវជននេះស្ថិតក្នុងកម្រិតណាមួយអាស្រ័យទៅលើអន្តរប្បច្ច័យជាច្រើន ដូចជាចំណេះដឹងរបស់យុវជនអំពីដំណើរការរៀបចំផែនការនិងថវិកា តួនាទីនិងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយយុវជនក៏ពុំទាន់យល់ច្បាស់អំពីសិទ្ធិចូលរួមរបស់ខ្លួនក្នុងនាមជាប្រជាពលរដ្ឋនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចនានា។ លើសពីនេះ ការចូលរួមរបស់យុវជនក៏មានឧបសគ្គខ្លះពាក់ព័ន្ធនឹងកត្តាសេដ្ឋកិច្ច ពេលវេលា អាណាព្យាបាល សន្តិសុខ និងកត្តាសង្គម ព្រមទាំងពុំទាន់មានភាពសកម្មក្នុងការលើកទឹកចិត្តនិងគាំពារពីអង្គភាពឬស្ថាប័នពាក់ព័ន្ធឱ្យបានខ្លាំងក្លា ទៅដល់អត្ថប្រយោជន៍នៃការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍឃុំ សង្កាត់ផងដែរ។

## ១.២-មូលដ្ឋានគតិយុត្តសម្រាប់រៀបចំសៀវភៅណែនាំ

សៀវភៅណែនាំសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ស្តីពីការលើកកម្ពស់ដល់ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់ ហៅកាត់ថា**សៀវភៅណែនាំសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ស្តីពី«ច.យ.ផ.ថ.»**ជាសៀវភៅណែនាំបច្ចេកទេសដែលផ្តោតទៅលើវត្តមានចូលរួមរបស់យុវជននៅក្នុងទិដ្ឋភាពនៃក្របខណ្ឌគតិយុត្តដែលមានស្រាប់ជាធរមានដូចជា៖

- គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ឆ្នាំ២០១១
- គោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៤
- សៀវភៅណែនាំបច្ចេកទេសស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៤
- ប្រកាសអន្តរក្រសួងលេខ០៨០ ផ.ក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងផែនការនិងក្រសួងមហាផ្ទៃ ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- ប្រកាសអន្តរក្រសួងលេខ០៧៤ ផ.ក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងផែនការនិងក្រសួងមហាផ្ទៃ ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំនិងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ
- ប្រកាសអន្តរក្រសួងលេខ០៧៣ ផ.ក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងផែនការនិងក្រសួងមហាផ្ទៃ ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំនិងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលសង្កាត់
- ប្រកាសអន្តរក្រសួងលេខ០១៤៩ ផ.ក ប្រ.ក ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២០ របស់ក្រសួងផែនការនិងក្រសួងមហាផ្ទៃ ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបំពេញបន្ថែមលើសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំនិងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- ប្រកាសអន្តរក្រសួងលេខ៣៨៤០ ប្រក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់
- សេចក្តីណែនាំលេខ០២៥ ស.ណ.ន. ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំនិងការអនុម័តថវិកាឃុំ សង្កាត់
- សេចក្តីណែនាំលេខ០៤៥ ស.ណ.ន. ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្តីពីការជ្រើសរើសតំណាងយុវជនចូលរួមជាសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់
- លិខិតបទដ្ឋានពាក់ព័ន្ធជាធរមាន។

## ១.៣-គោលបំណង

សៀវភៅណែនាំសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ស្តីពី«ច.យ.ផ.ថ.» គឺជាឯកសារណែនាំបំពេញបន្ថែមឬជំនួយសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ប្រើប្រាស់ក្នុងការលើកកម្ពស់ដល់ការចូលរួមរបស់យុវជនក្នុងដំណើរការនៃការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ និងការរៀបចំនិងការអនុម័តគម្រោងថវិកាឃុំ សង្កាត់។

## ១.៤-ការប្រើប្រាស់សៀវភៅណែនាំ

សៀវភៅណែនាំសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ស្តីពី«ច.យ.ផ.ថ.» ជាសៀវភៅណែនាំបច្ចេកទេសសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ប្រើប្រាស់ដើម្បីយល់ដឹងអំពីតួនាទី គោលការណ៍ និងអត្ថប្រយោជន៍នៃការចូលរួមរបស់យុវជន រួមទាំងអនុវត្តវិធីសាស្ត្រនានាសំដៅលើកកម្ពស់ការចូលរួមរបស់យុវជននៅក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់។

សៀវភៅណែនាំនេះមានបីផ្នែកសំខាន់ៗ រួមមានទីមួយជាសេចក្តីផ្តើមដែលបង្ហាញអំពីសនិទានភាព គោលបំណង និងការប្រើប្រាស់សៀវភៅណែនាំនេះ ទីពីរជាទិដ្ឋភាពទូទៅនៃការចូលរួមរបស់យុវជនដែលបង្ហាញអំពីវាក្យសព្ទឬពាក្យគន្លឹះៗ អត្ថប្រយោជន៍ តួនាទី និងគោលការណ៍នៃការចូលរួមរបស់យុវជន និងទីបីជាការលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់។



# ផ្នែកទី២

## ទិដ្ឋភាពទូទៅនៃការចូលរួមរបស់យុវជន





## ២.១-វាក្យសព្ទសំខាន់ៗ

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវសិក្សានិងឈ្វេងយល់នូវវាក្យសព្ទសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការចូលរួមរបស់យុវជនដូចខាងក្រោម៖

**យុវជន៖**សំដៅលើបុរសនិងស្ត្រីដែលមានសញ្ជាតិខ្មែរពីអាយុ១៥ឆ្នាំដល់៣០ឆ្នាំ នៅលីវឬរៀបការហើយ(តាមគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ឆ្នាំ២០១១)។

**ការចូលរួមរបស់យុវជន៖**សំដៅលើការចូលរួមដែលមានចរិតលក្ខណៈជាបុគ្គល ឬជាក្រុមដោយផ្ទាល់ឬដោយប្រយោល ដើម្បីបញ្ចេញទស្សនៈឬមតិយោបល់ផ្ទាល់របស់ខ្លួន ក្នុងការធ្វើសំណូមពរ ការឆ្លើយតប និងការសម្រេចចិត្តពាក់ព័ន្ធនឹងកិច្ចការនានានៃដំណើរការៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកាប្រចាំឆ្នាំនៃរដ្ឋបាលឃុំ សង្កាត់ ដែលមានក្នុងក្របខណ្ឌច្បាប់និងលិខិតបទដ្ឋាន។

**សមធម៌៖**សំដៅលើក្រុមឬយុវជនទាំងអស់ដែលត្រូវបានផ្តល់ឱកាសស្មើគ្នា ឬដូចគ្នានៅក្នុងការចូលរួមបញ្ចេញមតិឬយោបល់ ដើម្បីលើកឡើងនូវតម្រូវការសម្រាប់ដាក់ជូនរដ្ឋបាលឃុំ សង្កាត់ និងអាចចូលរួមចំណែកតាមដាននូវការអនុវត្តកិច្ចការនានាក្នុងការអភិវឌ្ឍឃុំ សង្កាត់។

**តម្លាភាព៖**សំដៅលើការបើកចំហព័ត៌មានទូលំទូលាយដល់ការចូលរួមរបស់យុវជន តាមរយៈការផ្សព្វផ្សាយជាសារធារណៈ ការសម្រេចចិត្ត និងការអនុវត្តនានា ក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់។

## ២.២-អត្ថប្រយោជន៍នៃការចូលរួមរបស់យុវជន

យុវជនអាចចូលរួមអភិវឌ្ឍមូលដ្ឋាន តាមរយៈការផ្ដល់នូវយោបល់និងការលើកឡើងនូវបញ្ហាឬតម្រូវការនានារបស់យុវជន ឱ្យក្រុមប្រឹក្សាឃុំ សង្កាត់បានដឹងនិងឆ្លើយតបនៅក្នុងដំណើរការនៃការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល ថវិកាប្រចាំឆ្នាំនៃរដ្ឋបាលឃុំ សង្កាត់ និងការអភិវឌ្ឍផ្សេងទៀត នៅឃុំ សង្កាត់។ បរិការណ៍នៃការចូលរួមរបស់យុវជនបានផ្ដល់ផលប្រយោជន៍ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងយុវជន ដូចខាងក្រោម៖

| ក្រុមប្រឹក្សាឃុំ សង្កាត់ | យុវជន |
|---|---|
| • ទទួលបាននូវធាតុចូល ចំណេះដឹងថ្មីៗ ចំណេះដឹងសំខាន់ៗពីយុវជនសម្រាប់ជាមូលដ្ឋានក្នុងការធ្វើសេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់<br>• ពង្រឹងឆន្ទៈនិងទំនុកចិត្តកាន់តែរឹងមាំថែមទៀត ក្នុងការបំពេញការងារបម្រើសេវាជូនប្រជាពលរដ្ឋ<br>• បង្កើនភាពស្និទ្ធស្នាល និងទំនាក់ទំនងល្អជាមួយនឹងប្រជាពលរដ្ឋ ជាពិសេសយុវជន<br>• អាចរៀបចំគម្រោងអភិវឌ្ឍ និងផ្ដល់សេវាសាធារណៈ ដែលឆ្លើយតបនឹងតម្រូវការជាក់លាក់របស់យុវជន ប្រសើរជាងមុន។ | • ទទួលនិងបង្កើនចំណេះដឹង ជំនាញ អាកប្បកិរិយាប្រកបដោយភាពវិជ្ជមាន ក្នុងទំនាក់ទំនងជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់<br>• ទទួលបានឱកាសចូលរួមក្នុងការអភិវឌ្ឍគ្រួសារ សហគមន៍ និងសង្គមជាតិ<br>• មានឱកាសចូលរួមក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការអភិវឌ្ឍមូលដ្ឋាន<br>• រួមចំណែកលើកកម្ពស់តម្លាភាព គណនេយ្យភាព និងការឆ្លើយតបក្នុងការផ្ដល់សេវាសាធារណៈ។ |

## ២.៣-គោលការណ៍នៃការចូលរួមរបស់យុវជន

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍នៃការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់ ដូចខាងក្រោម៖

**ការស្ម័គ្រចិត្ត៖**ក្រុមប្រឹក្សាឃុំ សង្កាត់ឈរលើគោលការណ៍ស្ម័គ្រចិត្តរបស់យុវជនដោយមិនដាក់កំហិតនិងមិនបង្ខិតបង្ខំយុវជនណាម្នាក់ ឱ្យចូលរួមនៅក្នុងដំណើរការនៃការអភិវឌ្ឍឃុំ សង្កាត់ និងកិច្ចការនានារបស់រដ្ឋបាលឃុំ សង្កាត់ឡើយ

**ការចែករំលែកព័ត៌មាន៖**ចែកចាយព័ត៌មានអំពីសាវតារ គោលបំណង សកម្មភាព ឬគម្រោង និងព្រឹត្តិការណ៍ពាក់ព័ន្ធនឹងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍





កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់ដល់យុវជនឱ្យបានគ្រប់គ្រាន់ ងាយយល់ និងទាន់ពេលវេលា

**ឧត្តមប្រយោជន៍របស់យុវជន៖**ប្រយោជន៍របស់យុវជនត្រូវបានយកចិត្តទុកដាក់ពិចារណានិងឆ្លើយតបចំពោះមតិ យោបល់ និងសំណើរបស់យុវជន សំដៅលើកកម្ពស់ឧត្តមប្រយោជន៍របស់យុវជនដោយផ្ទាល់ឬប្រយោលទាំងរយៈពេលខ្លីនិងរយៈពេលវែង

**ការគាំទ្រ៖**ការគាំទ្រដោយរដ្ឋបាលឃុំ សង្កាត់នូវធនធានហិរញ្ញវត្ថុ មិនមែនហិរញ្ញវត្ថុ ការកៀរគរដល់យុវជនឬក្រុមយុវជន ព្រមទាំងបង្កឱកាសនិងជំរុញលើកទឹកចិត្តដល់ការចូលរួមរបស់យុវជនទាំងមុនពេល កំលុងពេល និងក្រោយពេលប្រជុំឬព្រឹត្តិការណ៍ពាក់ព័ន្ធ

**សុវត្ថិភាព៖**ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវយកចិត្តទុកដាក់ខ្ពស់ចំពោះការចូលរួមរបស់យុវជនឱ្យទទួលបានសេចក្ដីសុខ ដោយត្រូវគិតគូរលើហានិភ័យនានាដែលអាចកើតឡើងជាយថាហេតុ ដូចជាបង្កគ្រោះថ្នាក់ដល់យុវជនក្នុងការចូលរួមអភិវឌ្ឍមូលដ្ឋាន។ ហានិភ័យមានដូចជាសុវត្ថិភាពក្នុងការធ្វើដំណើរ មធ្យោបាយទំនាក់ទំនង ការប្រឈមនឹងអំពើហិង្សា និងការរំលោភបំពាន ។ល។

**បរិយាបន្ននិងការមិនរើសអើង៖**ការដាក់បញ្ចូល ការដោះស្រាយ និងការឆ្លើយតបដោយសមធម៌និងមិនរើសអើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ចំពោះទស្សនៈរបស់យុវជន ក្នុងក្របខណ្ឌច្បាប់និងលិខិតបទដ្ឋានជាធរមាន។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រាកដថាទស្សនៈរបស់យុវជន ត្រូវបានទទួលយកទៅពិចារណាទាំងអស់ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ អាយុ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។

# ផ្នែកទី៣

## ការចូលរួមរបស់យុវជនក្នុងដំណើរការ
## រៀបចំនិងកសាងផែនការអភិវឌ្ឍន៍
## កម្មវិធីវិនិយោគបីឆ្នាំរំកិល
## និងថវិកានៃរដ្ឋបាលឃុំ សង្កាត់



## ៣.១-ការកំណត់ក្រុមគោលដៅយុវជនដែលត្រូវចូលរួម

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំពិនិត្យ ចងក្រង និងធ្វើបច្ចុប្បន្នភាពបញ្ជីព័ត៌មានអំពីក្រុមយុវជនដែលមាននៅក្នុងមូលដ្ឋានឃុំ សង្កាត់របស់ខ្លួន ដូចជាក្រុមប្រឹក្សាអភិវឌ្ឍន៍យុវជនឃុំ សង្កាត់ ក្រុមប្រឹក្សាយុវជនតាមសាលា និងបណ្ដាញយុវជននានា ដើម្បីភាពងាយស្រួលក្នុងការទាក់ទង ការផ្តល់ និងការទទួលព័ត៌មានពាក់ព័ន្ធនឹងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ និងការរៀបចំនិងការអនុម័តថវិកាឃុំ សង្កាត់ រួមទាំងកិច្ចប្រជុំផ្សេងៗ ឬព្រឹត្តិការណ៍នានា។ ក្រុមប្រឹក្សាឃុំ សង្កាត់អាចអាននិងស្វែងយល់ជំនួយស្មារតីអំពីព័ត៌មានរបស់ក្រុមឬបណ្ដាញយុវជនដូចមានក្នុងឧបសម្ព័ន្ធទី២នៃសៀវភៅណែនាំនេះ។

បន្ទាប់ពីការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ស្នើទៅប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍យុវជន ក្រុមប្រឹក្សាយុវជនតាមសាលា និងឬបណ្ដាញយុវជន ឱ្យផ្ដល់ព័ត៌មានមួយចំនួនអំពីប្រធាន អនុប្រធានក្រុមប្រឹក្សា និងព័ត៌មានផ្សេងៗទៅរដ្ឋបាលឃុំ សង្កាត់ដូចមានក្នុងទម្រង់ទី១។ មេឃុំ ចៅសង្កាត់ត្រូវយកចិត្តទុកដាក់ធ្វើបច្ចុប្បន្នភាពលើព័ត៌មានសង្ខេបរបស់ក្រុមយុវជនដែលមាននៅក្នុងមូលដ្ឋានឃុំ សង្កាត់ប្រចាំឆ្នាំ ឬអាចតាមពេលវេលាចាំបាច់។

### ទម្រង់ទី១៖ព័ត៏មានសង្ខេបរបស់ក្រុមយុវជនប្រចាំឆ្នាំ២០...

រដ្ឋបាលឃុំ សង្កាត់...........ក្រុង ស្រុក ខណ្ឌ......................... រាជធានី ខេត្ត...........

| ក-ព័ត៏មានទូទៅ | |
|---|---|
| ១-ឈ្មោះក្រុមប្រឹក្សាយុវជន ក្រុមយុវជន ក្លឹបយុវជន ឬបណ្ដាញយុវជន៖<br>............................................................................................................ | |
| ២-អាសយដ្ឋាន៖<br>............................................................................................................ | |
| ៣-ឈ្មោះអ្នកដឹកនាំ ប្រធាន ឬអ្នកតំណាង៖<br>........................................................................................................ | |
| ៤-ទូរសព្ទសម្រាប់ទំនាក់ទំនង៖<br>................................................ | អ៊ីមែល(ប្រសិនជាមាន)៖<br>........................................................ |





| ខ-ការគ្រប់គ្រងរបស់ក្រុមប្រឹក្សាយុវជនឬក្រុមយុវជន |
|---|
| ៥-វិសាលភាពតំបន់គោលដៅ៖<br>............................................................................................................ |
| ៦-ចំនួនសមាជិក៖...............នាក់(ស្រី.....នាក់) |
| ៧-បេសកកម្មរបស់ក្រុមប្រឹក្សាយុវជន ក្រុមយុវជន ឬអង្គការយុវជន៖<br>............................................................................................................ |
| ៨-កម្មវិធីអនុវត្តបច្ចុប្បន្ន៖<br>........................................................................................................។ |
| សម្គាល់៖ព័ត៌មានខាងលើនេះ គិតត្រឹមថ្ងៃទី.........ខែ............ឆ្នាំ២០........៕ |

ក្នុងកិច្ចប្រជុំជាមួយនឹងយុវជន ក្រុមប្រឹក្សាឃុំ សង្កាត់អាចពិភាក្សានិងឈ្វេងយល់ព័ត៌មានពាក់ព័ន្ធនឹងក្រុមយុវជន ដោយអាចធ្វើការឆ្លុះបញ្ចាំងសំណួរមួយចំនួន ដូចខាងក្រោម៖

- តើមានក្រុមប្រឹក្សាយុវជន ឬក្រុមយុវជន ឬក្លឹបយុវជន ឬបណ្ដាញណាខ្លះកំពុងដំណើរការនៅក្នុងមូលដ្ឋាន?
- តើមានស្ថាប័នណាខ្លះដែលធ្វើការពាក់ព័ន្ធនឹងយុវជន?
- តើអ្វីជាបញ្ហាចម្បងដែលពួកគេផ្តល់អាទិភាព? តើអ្វីជាអាទិភាពពាក់ព័ន្ធបំផុតដែលក្រុមប្រឹក្សាឃុំ សង្កាត់អាចសហការគ្នាបាន?

តាមរយៈកិច្ចប្រជុំនេះ ស្មៀនឃុំ សង្កាត់ឬអ្នកពាក់ព័ន្ធ អាចកត់ត្រាព័ត៌មានសង្ខេបអំពីយុវជនក្នុងតារាងបញ្ជីព័ត៌មានសម្រាប់ជាមូលដ្ឋានធ្វើបច្ចុប្បន្នភាពលើព័ត៌មានសង្ខេបរបស់ក្រុមយុវជន។

## តារាងបញ្ជីព័ត៌មានសម្រាប់ក្រុមយុវជន ឆ្នាំ២០........

រដ្ឋបាលឃុំ សង្កាត់...........ក្រុង ស្រុក ខណ្ឌ.............រាជធានី ខេត្ត...............

| ល.រ. | ឈ្មោះក្រុមយុវជន | ឈ្មោះតំណាង | ទីកន្លែង | បេសកកម្ម | លេខទូរសព្ទ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

## ៣.២-វិធីសាស្ត្រនៃការប្រមូលមតិនិងយោបល់របស់យុវជន

ផ្អែកលើសេចក្តីណែនាំបច្ចេកទេសនៃការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល សេចក្តីណែនាំស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំនិងការអនុម័តថវិការបស់រដ្ឋបាល ឃុំ សង្កាត់ និងឯកសារនានាដែលជាមូលដ្ឋានគតិយុត្តក្នុងដំណើរការនៃការរៀបចំផែនការនិងថវិកាឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់ដែលមានគណៈកម្មាធិការកសាងផែនការនិងថវិកា«គ.ផ.ថ.» ត្រូវពិគ្រោះយោបល់ជាមួយនឹងប្រជាពលរដ្ឋ។ ក្នុងការចូលរួមនេះដែរ «គ.ផ.ថ.»ត្រូវយកចិត្តទុកដាក់ជំរុញនិងកៀរគរឱ្យមានវត្តមានយុវជនដើម្បីប្រមូលតម្រូវការ សំណូមពរ និងបញ្ហានានាសម្រាប់ជាធាតុចូលក្នុងការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងគម្រោងថវិកាប្រចាំឆ្នាំនៃរដ្ឋបាលឃុំ សង្កាត់។

នៅក្នុងដំណើរការពិគ្រោះយោបល់ជាមួយនឹងប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់គួរពិចារណាយកចិត្តទុកដាក់ជំរុញការចូលរួមរបស់យុវជននៅក្នុងកិច្ចប្រជុំសាធារណៈ ដោយអនុវត្តតាមសកម្មភាពសំខាន់ដូចខាងក្រោម៖





### ក-មុនពេលកិច្ចប្រជុំ

- ជ្រើសរើសកន្លែងដែលយុវជនជាទូទៅអាចស្គាល់ និងងាយស្រួលស្វែងរក
- កំណត់កាលបរិច្ឆេទនិងពេលវេលាដែលសមស្របសម្រាប់យុវជននិងក្រុមយុវជនដែលត្រូវចូលរួម
- រៀបចំរបៀបវារៈនៃការប្រជុំ
- ផ្សព្វផ្សាយ ជូនដំណឹង ឬអញ្ជើញអ្នកពាក់ព័ន្ធ។

### ខ-កំលុងពេលកិច្ចប្រជុំ

- ក្រុមប្រឹក្សាត្រូវណែនាំខ្លួន មុនពេលចាប់ផ្តើម
- បង្ហាញពីគោលបំណងនៃការរៀបចំកិច្ចប្រជុំ
- រៀបចំឱ្យយុវជនអង្គុយក្បែរគ្នា ឬដាក់ក្នុងក្រុមតែមួយ
- បង្ហាញភាពរួសរាយ ភាពរាក់ទាក់ចំពោះយុវជន ឬក្រុមយុវជន
- បង្កបរិយាកាសស្និទ្ធស្នាលផ្សេងៗតាមដែលធ្វើទៅបាន
- បំផុសគំនិតឱ្យមានការចូលរួមផ្តល់យោបល់ពីយុវជនឱ្យបានគ្រប់ៗគ្នា
- មិនរំខាន ឬនិយាយកាត់សម្តីរបស់យុវជន នៅពេលដែលយុវជនកំពុងបញ្ចេញមតិ
- ត្រូវចេះបត់បែន និងប្រើប្រាស់វិធីសាស្ត្រទន់ភ្លន់ ដើម្បីទាញការពិភាក្សាឱ្យចំប្រធានបទ
- លើកទឹកចិត្តឱ្យយុវជនសួរសំណួរ និងចូលរួមឆ្លើយសំណួរឱ្យបានផុសផុល
- បង្ហាញ និងសង្ខេបពីចំណុចសំខាន់ៗ
- ជំរុញនិងលើកទឹកចិត្តដល់ការបញ្ចេញមតិរបស់យុវជន និងជៀសវាងការនិយាយពាក្យឬសម្តីដែលធ្វើឱ្យបាត់ឆន្ទៈចូលរួម ដូចជាថាមិនត្រឹមត្រូវ ឬខុសចំពោះការបញ្ចេញមតិរបស់យុវជន
- អ្វីដែលមិនគួរធ្វើក្នុងកំលុងពេលកិច្ចប្រជុំ
  + កុំទិតៀនដល់យុវជន
  + កុំនិយាយកាត់សម្តីក្នុងពេលកំពុងពិភាក្សា
  + កុំមានភាពហ្មត់ចត់ខ្លាំងពេក
  + កុំដាក់គំនាបលើយុវជន។

## គ-ក្រោយពេលកិច្ចប្រជុំ

- បន្ទាប់ពីប្រារព្ធកិច្ចប្រជុំ ប្រធានអង្គប្រជុំត្រូវធ្វើការបូកសរុបនូវរាល់មតិនិងយោបល់ទាំងអស់ ដែលបានលើកឡើង និងរៀបចំជារបាយការណ៍ឬកំណត់ហេតុ
- ផ្សព្វផ្សាយរបាយការណ៍ឬកំណត់ហេតុជាសាធារណៈ តាមរយៈក្ដារព័ត៌មានសាលាឃុំ សង្កាត់ សាលារៀន និងឬប្រព័ន្ធផ្សព្វផ្សាយសមស្របផ្សេងទៀត។

ក្នុងកិច្ចប្រជុំនេះដែរ ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់យល់ឃើញថាយុវជនឬក្រុមយុវជនមិនមានឱកាសបញ្ចេញមតិនិងយោបល់ដោយប្រការណាមួយ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រើប្រាស់មធ្យោបាយផ្សេងទៀតដែលអាចទទួលបានមតិនិងយោបល់តាមរយៈការរៀបចំកិច្ចពិភាក្សាជាមួយនឹងយុវជនឬក្រុមយុវជនដាច់ដោយឡែកពីប្រជាពលរដ្ឋទូទៅ ឬវិធីសាស្ត្រផ្សេងទៀតតាមរយៈការស្ទង់មតិ ឬវេទិកាសំណួរចម្លើយជាដើម។ វិធីសាស្ត្រនៃការពិភាក្សានេះក៏មានជំនួយស្មារតីបន្ថែមក្នុងឧបសម្ព័ន្ធទី៤ ទី៥ និងទី៦នៃសៀវភៅណែនាំនេះ។

## ៣.៣-ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

ប្រកាសអន្តរក្រសួងលេខ០៨០ ផ.ក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងផែនការនិងក្រសួងមហាផ្ទៃ ស្ដីពីការដាក់ឱ្យប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ បានតម្រូវឱ្យរដ្ឋបាលឃុំ សង្កាត់ធ្វើការពិគ្រោះយោបល់ជាមួយនឹងប្រជាពលរដ្ឋឱ្យបានទូលំទូលាយនៅក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ តាមជំហាននីមួយៗ។ តាមជំហាននៃការចូលរួមរបស់ប្រជាពលរដ្ឋនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវយកចិត្តទុកដាក់គិតគូរឱ្យមានវត្តមានរបស់យុវជនបានចូលរួមនៅតាមជំហាននីមួយៗ ក្នុងសកម្មភាពនៃការពិគ្រោះយោបល់ជាមួយនឹងប្រជាពលរដ្ឋនៅក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិលដូចខាងក្រោម៖

### ៣.៣.១-ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

ក្នុងដំណើរការនៃការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវខិតខំយកចិត្តទុកដាក់លើកកម្ពស់ឱ្យមានវត្តមានចូលរួមឬការផ្ដល់តម្រូវការនានារបស់យុវជននៅក្នុងជំហានទាំងបីស្របទៅតាមគោលការណ៍ដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំឃុំ សង្កាត់ ជាធរមាន។





## ជំហានទី១៖ការវិភាគស្ថានភាពនិងការកំណត់តម្រូវការអភិវឌ្ឍន៍ឃុំ សង្កាត់

### ក-ការផ្សព្វផ្សាយដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍

«គ.ផ.ថ.»ត្រូវផ្សព្វផ្សាយប្រតិទិននៃការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ដល់ប្រជាពលរដ្ឋ យុវជន តំណាងយុវជនដែលជាសមាជិក «**គ.ក.ន.ក.**» និងឬបណ្ដាញយុវជនតាមវិទ្យាល័យ អនុវិទ្យាល័យ និងក្រុមយុវជននានា នៅក្នុងឃុំ សង្កាត់។

### ខ-ការប្រមូលព័ត៌មានពីតម្រូវការរបស់មូលដ្ឋាន

«គ.ផ.ថ.»អញ្ជើញឬផ្ដល់ព័ត៌មានដល់យុវជននិងតំណាងយុវជនដែលជាសមាជិក«គ.ក.ន.ក.» និងឬបណ្ដាញយុវជនតាមវិទ្យាល័យ អនុវិទ្យាល័យ និងក្រុមយុវជននានា នៅឃុំ សង្កាត់ អំពីដំណើរការប្រមូលធាតុចូលសម្រាប់រៀបចំនិងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

ការប្រមូលតម្រូវការនេះត្រូវធ្វើឡើងនៅតាមភូមិឬថ្នាក់ភូមិ។ ការប្រមូលតម្រូវការអាចធ្វើឡើងតាមរយៈការពិគ្រោះយោបល់ថ្នាក់ភូមិនេះ ត្រូវមានការចូលរួមពីតំណាងគ្រួសារប្រជាពលរដ្ឋយ៉ាងតិច**៦០ភាគរយនៃចំនួនគ្រួសារសរុប**ក្នុងភូមិ(ស្ត្រីយ៉ាងតិច៣០ភាគរយ)។ ក្នុងដំណើរការនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវយកចិត្តទុកដាក់កៀរគរក្រុមយុវជននិងយុវតីក្នុងភូមិឱ្យចូលរួមយ៉ាងហោច២០ភាគរយក្នុងចំណោមប្រជាពលរដ្ឋ៦០ភាគរយនេះ។ ក្នុងករណី ប្រើប្រាស់បញ្ជីសំណួរឬបញ្ជីបញ្ហាតម្រូវការចំពោះឃុំ សង្កាត់ដែលស្ថិតក្នុងទីប្រជុំជនដែលមិនអាចរៀបចំប្រជុំថ្នាក់ភូមិបាន «គ.ផ.ថ.»ត្រូវយកចិត្តទុកដាក់បញ្ជូនបញ្ជីសំណួរឬបញ្ជីបញ្ហាតម្រូវការទាំងនេះទៅដល់ក្រុមយុជនឱ្យបានទាន់ពេលវេលា នៅក្នុងឃុំ សង្កាត់។

ក្នុងការជំរុញនិងការលើកកម្ពស់ដល់ការចូលរួមរបស់យុវជន «គ.ផ.ថ.»អាចប្រើវិធីសាស្ត្រចូលរួមផ្សេងទៀតដែលសមស្របដូចមានក្នុងចំណុចទី៣.២ស្ដីពីវិធីសាស្ត្រនៃការប្រមូលមតិនិងយោបល់របស់យុវជនខាងលើនេះ។

ក្នុងសកម្មភាពចូលរួមប្រជុំថ្នាក់ភូមិនេះ «គ.ផ.ថ.»ត្រូវប្រមូលតម្រូវការរបស់ប្រជាពលរដ្ឋដែលបានចូលរួមតាមនីតិវិធីជាធរមាន និងចុះបញ្ជីវត្តមានអ្នកដែលបានចូលរួមប្រជុំថ្នាក់ភូមិ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី ខេត្ត.............................
ក្រុង ខណ្ឌ ស្រុក........................
រដ្ឋបាលឃុំ សង្កាត់.....................

## ទម្រង់ទី២៖បញ្ជីវត្តមានប្រជុំថ្នាក់ភូមិ ស្ដីពីការប្រមូលតម្រូវការឬបញ្ហា

នៅភូមិ.................... ថ្ងៃ.................ខែ............ ឆ្នាំ................ព.ស.២៥......... ត្រូវនឹងថ្ងៃទី........ខែ.......... ឆ្នាំ២០...

| ល.រ. | គោត្តនាម និងនាម | ភេទ | អាយុ | អាសយដ្ឋាន | អង្គភាព | ភាពងាយរងគ្រោះ(សូមគូស✓) | | | | ហត្ថលេខាឬស្នាមមេដៃ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ក្រីក្រ១ | ក្រីក្រ២ | ពិការភាព | ជនជាតិដើមភាគតិច | | |
| ១ | | | | | | | | | | | |
| ២ | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |







អំពីការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់

## ជំហានទី២៖ការរៀបចំនិងការចងក្រងលើសេចក្ដីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

«គ.ផ.ថ.»អញ្ជើញឬផ្ដល់ព័ត៌មានដល់តំណាងយុវជនជាសមាជិក«គ.ក.ន.ក.» និងឬបណ្ដាញយុវជនតាមវិទ្យាល័យ អនុវិទ្យាល័យ និងក្រុមយុវជននានានៅក្នុងឃុំ សង្កាត់ ឱ្យបាន៣ឬ៤ថ្ងៃមុនកិច្ចប្រជុំ ដើម្បីចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្ដីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

## ជំហានទី៣៖ការពិនិត្យ ការអនុម័ត និងការផ្សព្វផ្សាយលើផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

បន្ទាប់ពីសេចក្ដីសម្រេចស្ដីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវបានចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវធ្វើការបោះពុម្ពនិងការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍នេះ ឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋនិងតំណាងយុវជននៅមូលដ្ឋាន។ លើសពីនេះ មេឃុំ ចៅសង្កាត់ត្រូវផ្សព្វផ្សាយខ្លឹមសារផែនការអភិវឌ្ឍន៍ឃុំ សង្កាត់( តារាង២.១៖ក្របខណ្ឌអភិវឌ្ឍន៍ឃុំ សង្កាត់ និងតារាង២.២៖ក្របខណ្ឌវិនិយោគរយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ ) តាមរយៈក្ដារព័ត៌មាន កិច្ចប្រជុំនានា វេទិកាសាធារណៈ សារព័ត៌មាន បណ្ដាញសង្គម និងតាមមធ្យោបាយសមស្របផ្សេងទៀត។

### ៣.៣.២-ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

ផ្អែកតាមផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់ត្រូវរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ នៅរៀងរាល់ឆ្នាំ។ ដើម្បីធានាឱ្យការរៀបចំនិងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់ត្រូវខិតខំយកចិត្តទុកដាក់ជំរុញយុវជនឱ្យចូលរួមក្នុងជំហាននីមួយៗដើម្បីផ្ដល់តម្រូវការរបស់យុវជនទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

«គ.ផ.ថ.»ត្រូវផ្សព្វផ្សាយប្រតិទិននៃការរៀបចំនិងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ឱ្យបានទូលំទូលាយដល់យុវជន និងតំណាងយុវជនដែលជាសមាជិក«គ.ក.ន.ក.» និងឬបណ្ដាញយុវជនតាមវិទ្យាល័យ អនុវិទ្យាល័យ ក្រុមយុវជននានា នៅក្នុងឃុំ សង្កាត់។ ប្រតិទិននេះត្រូវផ្សព្វផ្សាយតាមរយៈក្ដារព័ត៌មាន កិច្ចប្រជុំនានា វេទិកាសាធារណៈ សារព័ត៌មាន បណ្ដាញសង្គម និងតាមមធ្យោបាយសមស្របយ៉ាងហោច៣ឬ៤ថ្ងៃ មុនដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល។

## ជំហានទី១៖ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋានសម្រាប់រៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

### ក-ការវិភាគស្ថានភាពទូទៅ

មេឃុំ ចៅសង្កាត់ត្រូវអញ្ជើញតំណាងយុវជនជាសមាជិក«គ.ក.ន.ក.» និងឬបណ្តាញយុវជនតាមវិទ្យាល័យ អនុវិទ្យាល័យ និងក្រុមយុវជននានា នៅក្នុងឃុំ សង្កាត់ ឱ្យចូលរួមប្រជុំពិនិត្យនិងវិភាគស្ថានភាពឃុំ សង្កាត់អំពីការកំណត់បញ្ហា តម្រូវការ និងដំណោះស្រាយ។

### ខ-ការពិគ្រោះយោបល់តាមភូមិនីមួយៗ

បន្ទាប់ពីមេភូមិនីមួយៗស្រង់យកបញ្ហា តម្រូវការ និងដំណោះស្រាយដែលពាក់ព័ន្ធនានានៅតាមភូមិរៀងៗខ្លួន។ មេភូមិធ្វើកិច្ចការមួយចំនួននៅមុនពេលធ្វើការបង្ហាញនិងការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួន ដូចជា៖

- ផ្តល់ព័ត៌មានអំពីពេលវេលា ទីកន្លែង និងកាលបរិច្ឆេទនៃការពិគ្រោះយោបល់ដល់គ្រប់គ្រួសារប្រជាពលរដ្ឋនិងក្រុមយុវជននៅក្នុងភូមិ ឱ្យបានមុនយ៉ាងតិច៣ថ្ងៃតាមរយៈការអញ្ជើញផ្ទាល់មាត់ លិខិតអញ្ជើញ បណ្ណព័ត៌មាន បណ្តាញសង្គម ឧគ្ឃោសនសព្ទ ការបិទផ្សាយនៅទីស្នាក់ការភូមិ ក្តារព័ត៌មាន និងឬតាមមធ្យោបាយផ្សេងទៀត
- មេភូមិត្រូវអញ្ជើញយុវជនចូលរួមឱ្យបានច្រើនយ៉ាងហោចណាស់២០ភាគរយក្នុងចំណោម៦០ភាគរយនៃចំនួនគ្រួសារសរុបក្នុងភូមិដែលត្រូវអញ្ជើញចូលរួមប្រជុំពិគ្រោះយោបល់។

ក្នុងការប្រជុំថ្នាក់ភូមិ មេភូមិត្រូវប្រមូលតម្រូវការរបស់ប្រជាពលរដ្ឋដែលបានចូលរួមតាមនីតិវិធីជាធរមាន និងចុះបញ្ជីវត្តមានអ្នកដែលបានចូលរួមប្រជុំថ្នាក់ភូមិដូចមានក្នុងទម្រង់ទី២នៃចំណុចទី**៣.៣.១**ខាងលើនេះ។

ក្នុងករណី ការជួបប្រជុំជាមួយនឹងប្រជាពលរដ្ឋនិងយុវជនតាមភូមិមានការលំបាក មេភូមិអាចប្រើប្រាស់ទម្រង់ប្រមូលព័ត៌មានជាលាយលក្ខណ៍អក្សរ ដោយការចុះជួបតាមផ្ទះ និងឬផ្ញើទម្រង់តារាងកំណត់បញ្ហាឬតម្រូវការដល់ក្រុមយុវជនឬបណ្តាញយុវជនក្នុងឃុំ សង្កាត់ឱ្យបំពេញនិងកំណត់ពេលវេលាផ្ញើត្រលប់ឱ្យបានជាក់លាក់។ ម៉្យាងទៀត មេភូមិអាចផ្ញើនិងបញ្ជូនតារាងកំណត់បញ្ហាឬតម្រូវការនេះតាមរយៈបណ្តាញសង្គមដែលសមស្រប។





## ជំហានទី២៖ការរៀបចំនិងការចងក្រងលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

ផ្អែកតាមសិក្ខាសាលាសមាហរណកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ «គ.ផ.ថ.» ត្រូវកែសម្រួលតារាង១.១.គនៃសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ឡើងវិញ។ តាមរយៈការកែសម្រួលតារាង១.១.គនេះ មេភូមិនីមួយៗត្រូវស្រង់យកឈ្មោះគម្រោងឬសកម្មភាពដែលស្ថិតនៅតាមភូមិរៀងៗខ្លួនចេញពីតារាង១.១.គ ដើម្បីយកទៅធ្វើការបង្ហាញនិងដាក់ពិគ្រោះយោបល់ និងស្រង់យកយោបល់ពីប្រជាពលរដ្ឋនិងយុវជនក្នុងភូមិរបស់ខ្លួន។ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ភូមិក្នុងជំហានទី២នេះ មេភូមិត្រូវយកចិត្តទុកដាក់ឱ្យមានវត្តមានចូលរួមពីយុវជននិងឬក្រុមយុវជនតាមនីតិវិធី ដូចក្នុងចំណុច«ខ»នៃជំហានទី១ខាងលើនេះ។

## ជំហានទី៣៖ការពិនិត្យ ការអនុម័ត និងការផ្សព្វផ្សាយលើកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

មុនដំណើរការកិច្ចប្រជុំអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវជូនដំណឹងឬចេញលិខិតអញ្ជើញដោយផ្ទាល់និងឬជូនដំណឹងតាមរយៈបណ្តាញសង្គមដល់តំណាងយុវជនជាសមាជិក «គ.ក.ន.ក.» និងឬតំណាងក្រុមយុវជនផ្សេងទៀត ដើម្បីចូលរួមក្នុងនាមជាអ្នកសង្កេតការណ៍ឱ្យបានមុនយ៉ាងតិច៣ថ្ងៃ ដោយបញ្ជាក់អំពីពេលវេលា ទីកន្លែង និងកាលបរិច្ឆេទនៃកិច្ចប្រជុំអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

បន្ទាប់ពីសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់បានចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវធ្វើការបោះពុម្ព និងផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលនេះឱ្យបានទូលំទូលាយទៅដល់ប្រជាពលរដ្ឋ និងតំណាងយុវជននៅមូលដ្ឋានឃុំ សង្កាត់។ លើសពីនេះ មេឃុំ ចៅសង្កាត់ ត្រូវផ្សព្វផ្សាយខ្លឹមសារកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់( តារាង២.២ និងតារាង២.៣ ) តាមរយៈក្តារព័ត៌មាន កិច្ចប្រជុំនានា វេទិកាសាធារណៈ សារព័ត៌មាន បណ្តាញសង្គម និងតាមមធ្យោបាយដែលសមស្របផ្សេងទៀត។ ម៉្យាងទៀត «គ.ផ.ថ»ត្រូវប្រើប្រាស់នីតិវិធីនៃការរៀបចំកិច្ចប្រជុំផ្សព្វផ្សាយតាមឧបសម្ព័ន្ធទី៤ក្នុងផ្នែកទី៤ស្តីពីឧបសម្ព័ន្ធជំនួយស្មារតីនៅពេលរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់នៃសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំនិងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

## ៣.៤-ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងអនុម័តគម្រោងថវិកាឃុំ សង្កាត់

ក្នុងដំណើរការរៀបចំនិងអនុម័តថវិកាឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវខិតខំយកចិត្តទុកដាក់លើកកម្ពស់ឱ្យមានវត្តមានចូលរួមរបស់យុវជននៅក្នុងដំណាក់កាលនីមួយៗតាមគោលការណ៍ដែលបានកំណត់ក្នុងនីតិវិធីនៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំនិងការអនុម័តថវិការបស់រដ្ឋបាលឃុំ សង្កាត់ជាធរមាន។

### ៣.៤.១-ការផ្សព្វផ្សាយជំហានសង្ខេបស្ដីពីដំណើរការរៀបចំនិងអនុម័តថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ

បន្ទាប់ពីគណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ សង្កាត់«គ.ផ.ថ.»បានប្រជុំកំណត់កាលបរិច្ឆេទនៃជំហានរៀបចំនិងអនុម័តថវិការបស់រដ្ឋបាលឃុំ សង្កាត់តាមទម្រង់ឧបសម្ព័ន្ធទី៣នៃសេចក្ដីណែនាំលេខ០២៥ ស.ណ.ន. ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ស្ដីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំនិងការអនុម័តថវិការបស់រដ្ឋបាលឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវផ្សព្វផ្សាយជំហានសង្ខេបស្ដីពីដំណើរការរៀបចំនិងអនុម័តថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ នៅសាលាឃុំ សង្កាត់ សាលារៀន វត្តអារាម និងទីប្រជុំជននានា ឬអាចផ្សព្វផ្សាយតាមមធ្យោបាយសមស្រប ដូចជាតាមរយៈបណ្ដាញសង្គម កម្មវិធីជួបជុំនានា ឧគ្ឃោសនសព្ទ ឬបណ្ណព័ត៌មាន មុនជំហានទី១នៃជំហានសង្ខេប។

### ៣.៤.២-ការប្រជុំពិគ្រោះយោបល់លើសេចក្ដីព្រាងគម្រោងថវិកាសង្ខេបឃុំ សង្កាត់

ក្នុងដំណើរការពិគ្រោះយោបល់លើសេចក្ដីព្រាងគម្រោងថវិកាសង្ខេបឃុំ សង្កាត់ប្រចាំឆ្នាំ មេឃុំ ចៅសង្កាត់ត្រូវយកចិត្តទុកដាក់ជំរុញឱ្យយុវជន តំណាងយុវជនជាសមាជិក«គ.ក.ន.ក.» និងតំណាងក្រុមយុវជនផ្សេងទៀត ឱ្យចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្ដីព្រាងគម្រោងថវិកាសង្ខេបឃុំ សង្កាត់នៅតាមទីតាំងបិទផ្សាយនានា សាលាឃុំ សង្កាត់ សាលារៀន សាលាបុណ្យ មណ្ឌលសុខភាព វត្តអារាម និងទីប្រជុំជននានា ដែលបានកំណត់ក្នុងសេចក្ដីណែនាំស្ដីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំនិងការអនុម័តថវិការបស់រដ្ឋបាលឃុំ សង្កាត់។ ទម្រង់ថវិកាសង្ខេបឃុំ សង្កាត់ជាទំហំក្រដាសផ្ទាំងធំសម្រាប់បិទផ្សព្វផ្សាយដែលបានកំណត់ក្នុងសេចក្ដីណែនាំលេខ០២៥ ស.ណ.ន. ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ ស្ដីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំនិងការអនុម័តថវិការបស់រដ្ឋបាលឃុំ សង្កាត់ ដូចមានក្នុងឧបសម្ព័ន្ធទី៧នៃសៀវភៅណែនាំនេះ។





ផ្នែកទី៣

អំពីការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកានៃរដ្ឋបាលឃុំ សង្កាត់

### ៣.៤.៣-ការអនុម័តនិងការផ្សព្វផ្សាយគម្រោងថវិកាប្រចាំឆ្នាំឃុំ សង្កាត់

ផ្អែកតាមកាលបរិច្ឆេទនៃការប្រជុំអនុម័តសេចក្ដីព្រាងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវជូនដំណឹងដល់ប្រធានឬតំណាងក្រុមយុវជន អំពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អនុម័តលើគម្រោងថវិកាប្រចាំឆ្នាំឃុំ សង្កាត់ នៅសាលាឃុំ សង្កាត់។ មេឃុំ ចៅសង្កាត់អាចពិចារណាចំនួនយុវជនឬតំណាងយុវជនដែលត្រូវចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យស្របតាមពេលវេលា និងទីកន្លែងប្រជុំ ព្រមទាំងលើកទឹកចិត្តយុវជនឱ្យចូលរួមផ្ដល់យោបល់និងលើកសំណើឬសំណូមពរដែលពាក់ព័ន្ធនឹងផលប្រយោជន៍យុវជន។

បន្ទាប់ពីគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ត្រូវបានផ្ដល់អនុលោមភាពជាផ្លូវការ មេឃុំ ចៅសង្កាត់ត្រូវបិទផ្សាយគម្រោងថវិកាសង្ខេបឃុំ សង្កាត់ដែលបានកែសម្រួល នៅតាមទីតាំងដែលបានកំណត់ក្នុងសេចក្ដីណែនាំលេខ០២៥ ស.ណ.ន. ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ស្ដីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំនិងការអនុម័តថវិការបស់រដ្ឋបាលឃុំ សង្កាត់។

រដ្ឋបាលឃុំ សង្កាត់អាចប្រើប្រាស់បណ្ដាញសង្គមឬមធ្យោបាយផ្សេងៗទៅតាមលទ្ធភាពដែលអាចធ្វើទៅបានដើម្បីផ្សព្វផ្សាយគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់។



# ឧបសម្ព័ន្ធ



## ឧបសម្ព័ន្ធទី១៖គោលវិធីនៃការចូលរួមរបស់យុវជន

ការចូលរួមរបស់យុវជនអាចរៀបចំតាមរយៈគោលវិធីចំនួនបី៖កិច្ចពិគ្រោះយោបល់ កិច្ចសហការ និងភាពជាអ្នកដឹកនាំ។ ការជ្រើសរើសគោលវិធីណាមួយសម្រាប់ការចូលរួមរបស់យុវជន គឺអាស្រ័យទៅតាមបរិបទ និងគោលបំណងនៃសកម្មភាពឬដំណើរការ។

១. កិច្ចពិគ្រោះយោបល់៖ក្រុមប្រឹក្សាឃុំ សង្កាត់ពិភាក្សាជាមួយនឹងយុវជន ដើម្បីឈ្វេងយល់ពីទស្សនៈរបស់យុវជនពាក់ព័ន្ធនឹងជីវិតរស់នៅ និងបទពិសោធរបស់យុវជន។ នៅក្នុងកម្រិតនេះ ក្រុមប្រឹក្សាឃុំ សង្កាត់គួរស្តាប់និងអាចទទួលយកទស្សនៈរបស់យុវជនមកដាក់ជារបៀបវារៈ និងផែនការសកម្មភាពរបស់រដ្ឋបាលឃុំ សង្កាត់។

   ឧទាហរណ៍៖នៅក្នុងជំហានទី១នៃដំណើរការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ «គ.ផ.ថ.»ត្រូវរៀបចំនិងប្រមូលទិន្នន័យតាមរយៈការប្រជុំនៅក្នុងភូមិ។ ជាក់ស្តែង ប្រហែល៣ឆ្នាំចុងក្រោយនេះ អត្រាយុវជនសេពគ្រឿងញៀននៅក្នុងសហគមន៍មានការកើនឡើងគួរឱ្យកត់សម្គាល់។ ដូច្នេះ មេភូមិបានដាក់បញ្ចូលបញ្ហាយុវជនសេពគ្រឿងញៀនជាប្រធានបទប្រជុំនៅតាមភូមិ។ មេភូមិបានអញ្ជើញយុវជននៅក្នុងភូមិរបស់ខ្លួន ដើម្បីចូលរួមក្នុងការប្រជុំពិគ្រោះយោបល់នៅតាមភូមិ។

២. កិច្ចសហការ៖ក្រុមប្រឹក្សាឃុំ សង្កាត់ និងយុវជន អាចផ្តួចផ្តើមគំនិតរួមគ្នា ពិភាក្សាលើគំនិតរួម និងឯកភាពជាគោលការណ៍ ដើម្បីសម្រេចបានឧត្តមប្រយោជន៍របស់យុវជន ហើយដាក់ជូនក្រុមប្រឹក្សាអនុម័ត។ ឧទាហរណ៍៖ក្នុងកិច្ចប្រជុំពិគ្រោះយោបល់តាមភូមិ «គ.ផ.ថ»សួរអំពីតម្រូវការរបស់យុវជន ហើយបានឯកភាពជាគោលការណ៍ជាមួយនឹងយុវជនអំពីតម្រូវការជាអាទិភាពរបស់យុវជន។ ដូច្នេះ «គ.ផ.ថ»ដាក់សំណើជូនក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការសម្រេច។

៣. ភាពជាអ្នកដឹកនាំ៖យុវជនដើរតួជាអ្នកដឹកនាំក្នុងការសម្រេចចិត្ត ដូចជាការចូលរួមផ្តល់តម្រូវការក្នុងការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។ រីឯក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីជាអ្នកសម្របសម្រួលក្នុងដំណើរការដឹកនាំរបស់យុវជននេះ។

   ឧទាហរណ៍៖ក្រុមប្រឹក្សាមានកញ្ចប់ថវិកាឱ្យយុវជនសម្រេចប្រើលើគម្រោងឬសកម្មភាពណាមួយដែលជាតម្រូវការចាំបាច់របស់យុវជន។ យុវជនជាអ្នកអនុវត្តគម្រោងឬសកម្មភាពដោយផ្ទាល់ដោយមានការគាំទ្រពីក្រុមប្រឹក្សាឃុំ សង្កាត់។



## ឧបសម្ព័ន្ធទី២៖ក្រុមតំណាងយុវជននៅក្នុងមូលដ្ឋានឃុំ សង្កាត់

ការចូលរួមរបស់យុវជនអាចធ្វើឡើងជាលក្ខណៈបុគ្គលឬតាមរយៈអ្នកតំណាង។ ការកៀរគរយុវជនឱ្យយុវជនចូលរួមជាលក្ខណៈបុគ្គលអាចមានការលំបាកសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ព្រោះនៅពេលមានការចូលរួមពីសំណាក់យុវជនជាលក្ខណៈបុគ្គលដែលមិនមានរចនាសម្ព័ន្ធការងារ ពួកគេតែងមានផលប្រយោជន៍បុគ្គលខុសៗគ្នាជាច្រើន ឬមានចំណាប់អារម្មណ៍លើប្រធានបទផ្សេងៗគ្នា។ ចំណែក ការលើកកម្ពស់ការចូលរួមរបស់យុវជនជាក្រុមដោយផ្ទាល់ ឬតាមរយៈអ្នកតំណាង អាចមានភាពងាយស្រួលនិងប្រសិទ្ធភាព ដោយសារតែមានរចនាសម្ព័ន្ធ សមាជិក និងជនបង្គោលសម្រាប់ទំនាក់ទំនង។ ជាទូទៅ ក្រុមតំណាងយុវជនដែលអាចមានវត្តមាននៅក្នុងមូលដ្ឋាន រួមមានក្រុមប្រឹក្សាយុវជននៅតាមអនុវិទ្យាល័យ និងវិទ្យាល័យ ក្រុមយុវជន ក្លឹបយុវជន ឬបណ្តាញយុវជន ដែលបង្កើតឡើងដោយស្ថាប័នណាស្របតាមលិខិតបទដ្ឋានជាធរមាន។

### ក្រុមប្រឹក្សាយុវជននៅតាមអនុវិទ្យាល័យ និងតាមវិទ្យាល័យ៖

ក្រុមប្រឹក្សាយុវជនត្រូវបានបង្កើតឡើងនៅតាមអនុវិទ្យាល័យនិងតាមវិទ្យាល័យ ក្នុងគោលបំណងជួយការងារក្នុងសាលារៀន និងផ្តល់ឱកាសឱ្យកុមារនិងយុវជនបានសិក្សារៀនសូត្របន្ថែមពីការងារដែលកើតមានឡើងក្នុងសាលារៀន ដូចជាសកម្មភាពហ្វឹកហាត់ដឹកនាំនិងគ្រប់គ្រងដើម្បីអាចអភិវឌ្ឍបំណិនទទួលខុសត្រូវត្រិះរិះ ពិចារណា ដោះស្រាយបញ្ហា និងទំនាក់ទំនងបន្ថែមលើការសិក្សាមុខវិជ្ជាក្នុងថ្នាក់រៀន។

ដើម្បីលើកកម្ពស់ដល់ការចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់អាចកៀរគរប្រមូលយុវជនពីក្រុមប្រឹក្សាយុវជននៅតាមអនុវិទ្យាល័យ និងតាមវិទ្យាល័យក្នុងមូលដ្ឋាន ដោយសារនៅគ្រប់អនុវិទ្យាល័យនិងវិទ្យាល័យមានក្រុមប្រឹក្សាយុវជនដែលមានរចនាសម្ព័ន្ធស្ថិតក្រោមការដឹកនាំរបស់នាយកសាលា និងសម្របសម្រួលគាំទ្រដោយលោកគ្រូ អ្នកគ្រូ។ លើសពីនេះ អនុវិទ្យាល័យ និងឬវិទ្យាល័យកំពុងអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន។ សិស្សានុសិស្សដែលជាសមាជិកនៃក្រុមប្រឹក្សាយុវជនចេះពីវិធីកំណត់និងដោះស្រាយបញ្ហាប្រឈមនានាដែលកើតឡើងនៅក្នុងសាលារៀន ផ្ទះ និងឬសហគមន៍។ នៅពេលដែលក្រុមប្រឹក្សាកៀរគរប្រមូលយុវជននៅតាមអនុវិទ្យាល័យនិងវិទ្យាល័យ ពួកគេអាចលើកបញ្ហាដែលបានកំណត់តាមការស្រាវជ្រាវ សម្ភាសន៍ និងការប្រមូលមតិពីយុវជនដទៃទៅកាន់ក្រុមប្រឹក្សា។

### ក្រុមយុវជន ក្លឹបយុវជន និងបណ្តាញយុវជន៖

ក្រៅពីក្រុមប្រឹក្សាយុវជននៅតាមអនុវិទ្យាល័យនិងតាមវិទ្យាល័យ ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រមូលយុវជនពីបណ្តាញយុវជន ក្លឹបយុវជន ឬក្រុមយុវជន នៅក្នុងមូលដ្ឋានដែលបង្កើតឡើងដោយក្រុមយុវជនខ្លួនឯងផ្ទាល់ ឬមានការគាំទ្រពីស្ថាប័នរដ្ឋ ឬសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល។ ឧទាហរណ៍៖ក្រុមយុវជនកាកបាទក្រហម ក្រុមយុវជនកាយរឹទ្ធ ក្រុមតំណាងយុវជន បណ្តាញយុវជនរបស់អង្គការទស្សនៈពិភពលោក ក្រុមយុវជនបរិស្ថាន។ល។ បណ្តាញយុវជន ក្លឹបយុវជន ឬក្រុមយុវជនទាំងនេះ អាចមានគោលបំណងនិងការអនុវត្តសកម្មភាពផ្សេងៗពីគ្នា ប៉ុន្តែនៅក្នុងគោលបំណងបម្រើផលប្រយោជន៍ដល់យុវជនឬសហគមន៍ទាំងមូល។

ឧបសម្ពន្ធ

## ឧបសម្ព័ន្ធទី៣៖សំណួរគន្លឹះសម្រាប់រៀបចំកិច្ចប្រជុំបែបយុវជនមេត្រី

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រើប្រាស់បញ្ជីសំណួរគន្លឹះជាជំនួយ ដើម្បីរៀបចំកិច្ចប្រជុំជាមួយនឹងយុវជន។ ចំពោះបញ្ជីសំណួរនេះក៏អាចយកទៅប្រើប្រាស់នៅពេលរៀបចំការពិគ្រោះយោបល់ជាមួយនឹងយុវជនតាមរយៈវេទិកាសំណួរចម្លើយ កិច្ចពិភាក្សាជាមួយនឹងក្រុមជាក់លាក់ ឬវេទិកាសាធារណៈជាដើម។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រើប្រាស់បញ្ជីសំណួរសំខាន់ៗដូចខាងក្រោម៖

- តើកិច្ចប្រជុំមានគោលបំណងអ្វី?
- តើអ្នកណាខ្លះដែលត្រូវអញ្ជើញឱ្យចូលរួមដើម្បីសម្រេចបាននូវគោលបំណងខាងលើ?
- តើកិច្ចប្រជុំប្រភេទណាដែលសមស្របដើម្បីសម្រេចគោលបំណងដែលបានកំណត់?
- តើកិច្ចប្រជុំនេះ គួរដំណើរការទៅដោយរបៀបណា?
- តើក្រុមប្រឹក្សាឃុំ សង្កាត់គួរធ្វើដូចម្ដេច ដើម្បីឱ្យកិច្ចប្រជុំនេះកាន់តែមានការចាប់អារម្មណ៍ខ្លាំង?
- តើទីកន្លែងណាដែលសមស្របបំផុតសម្រាប់ជួបប្រជុំ?
- តើសម្ភារៈនិងឧបករណ៍អ្វីខ្លះដែលត្រូវការ?
- តើពេលណាដែលសមស្របបំផុតសម្រាប់អ្នកចូលរួម?
- តើអ្នកណាអាចសម្របសម្រួលកិច្ចប្រជុំបាន?
- តើត្រូវផ្ដល់ព័ត៌មាន ឬអញ្ជើញអ្នកចូលរួមដោយវិធីណា?



## ឧបសម្ព័ន្ធទី៤៖ការស្ទង់មតិ

ក្រុមប្រឹក្សាឃុំ សង្កាត់អាចរៀបចំការស្ទង់មតិតាមរយៈបញ្ជីសំណួរក្នុងគោលបំណងប្រមូលមតិឬយោបល់និងសំណូមពរពីក្រុមយុវជន។ ការស្ទង់មតិអាចធ្វើតាមរូបភាព ដូចខាងក្រោម៖



**ការស្ទង់មតិលើយុវជនទូទៅ៖**ការស្ទង់មតិលើយុវជន និងការអនុវត្តចំពោះយុវជនដែលទទួលរងផលប៉ះពាល់ទាំងអស់តាមរយៈការសម្ភាស។ ការធ្វើបែបនេះអាចដំណើរការទៅបាន ប្រសិនបើយុវជនដែលត្រូវធ្វើសម្ភាសន៍មានចំនួនកំណត់។ ឧទាហរណ៍៖ក្រុមប្រឹក្សាឃុំ សង្កាត់ចង់ដឹងថាតើកុមារនិងយុវជន ចង់ឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ជួយអ្វីខ្លះដល់ពួកគេ? ដូច្នេះត្រូវធ្វើការស្ទង់មតិមួយនៅក្នុងសាលាបឋមសិក្សា និងអនុវិទ្យាល័យទាំងអស់។



**ការស្ទង់មតិជាតំណាង(សំណាក)៖**ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់ចង់បានទស្សនៈរួមរបស់យុវជនភាគច្រើននៅឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់គួរធ្វើការស្ទង់មតិជាតំណាងដោយត្រូវជ្រើសរើសយុវជនមួយចំនួនតូចធ្វើជាតំណាងឱ្យយុវជននិងយុវតីទាំងអស់សម្រាប់ធ្វើការស្ទង់មតិ។ ឧទាហរណ៍៖ក្រុមប្រឹក្សាឃុំ សង្កាត់ចង់ដឹងថា តើយុវជននិងយុវតីពេញចិត្តនឹងការងារផ្ដល់សេវាច្រកចេញចូលតែមួយឃុំ សង្កាត់ដែរឬទេ? ក្រុមប្រឹក្សាគួរធ្វើការស្ទង់មតិជាតំណាងដោយជ្រើសរើសយុវជនមួយក្រុមចំនួន១០០នាក់សម្រាប់ធ្វើការសម្ភាស។ ចំនួនដែលជ្រើសរើសនេះតំណាងឱ្យយុវជនទាំងអស់ក្នុងឃុំ សង្កាត់។

ការស្ទង់មតិអាចប្រើប្រាស់ទម្រង់ជាលាយលក្ខណ៍អក្សរ ឬការស្ទង់មតិផ្ទាល់មាត់។ ការស្ទង់មតិជាលាយលក្ខណ៍អក្សរត្រូវរៀបចំជាបញ្ជីសំណួរ ហើយត្រូវចែកដោយផ្ទាល់នៅក្នុងចំណោមក្រុមគោលដៅ ឬដាក់នៅកន្លែងងាយស្រួលស្វែងរក។ អ្នកផ្ដល់ចម្លើយត្រូវបំពេញបញ្ជីសំណួរ ហើយយកទៅដាក់នៅកន្លែងប្រមូលយកបញ្ជីសំណួរវិញ ស្របតាមការណែនាំ។

ការស្ទង់មតិផ្ទាល់មាត់ ជាការសម្ភាសន៍តាមរយៈការជួបមុខគ្នាផ្ទាល់ ឬតាមរយៈទូរសព្ទដោយផ្អែកទៅលើបញ្ជីសំណួរដែលបានរៀបចំជាស្រេច។ ការស្ទង់មតិអាចប្រើប្រាស់សំណួរពីរប្រភេទ គឺសំណួរបិទ និងបញ្ជីសំណួរបើក មានដូចជា៖

- **សំណួរបិទ៖**ជាប្រភេទសំណួរដែលផ្ដល់នូវចម្លើយសម្រាប់ជ្រើសរើស ហើយអ្នកឆ្លើយត្រូវជ្រើសរើសយកជម្រើសណាមួយ ឧទាហរណ៍៖សំណួរ«តើការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់មានសារៈសំខាន់ដែរឬទេ?»
  ចម្លើយអាចគូសបានមាន ☐ បាទឬចាស ☐ ទេ
- **សំណួរបើក៖**ជាប្រភេទសំណួរមិនកំណត់ចម្លើយថាបាទឬចាសឬទេឡើយ។ចម្លើយមិនកំណត់ទេ

អ្នកផ្តល់ចម្លើយអាចចែករំលែកមតិឬយោបល់របស់ខ្លួនជាលក្ខណៈបុគ្គល។ការវិភាគបញ្ជីសំណួរបើកត្រូវចំណាយពេលច្រើន អ្នកផ្តល់ចម្លើយមានឱកាសបកស្រាយចម្លើយរបស់ខ្លួនបានទូលំទូលាយ។ ឧទាហរណ៍៖តើអ្នកយល់យ៉ាងណាពីការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់?។

**ឧទាហរណ៍ទី១៖**កម្រងសំណួរស្តីពីការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

**១. តើប្អូនធ្លាប់ចូលរួមប្រជុំពិគ្រោះយោបល់នៅតាមភូមិដែរឬទេ?**

☐ ក-ធ្លាប់( ប្រសិនជាធ្លាប់ សូមបន្តទៅសំណួរទី២ )

☐ ខ-មិនធ្លាប់ ប្រសិនជាមិនធ្លាប់ សូមរំលងទៅសំណួរទី៣ )

**២. តើប្អូនបានលើកពីបញ្ហាឬតម្រូវការរបស់ប្អូន ក្នុងពេលប្រជុំនៅតាមភូមិដែរឬទេ?**

☐ ក-បាទ/ចាស ☐ ខ-ទេ

**៣. តើប្អូនគិតថាមូលហេតុអ្វីបានជាប្អូនមិនធ្លាប់ចូលរួមប្រជុំនៅតាមភូមិ?**

.............................................................................................................

.............................................................................................................

**៤. ក្នុងចំណោមបញ្ហាខាងក្រោម។ តើបញ្ហាណាខ្លះដែលប្អូនគិតថាជាបញ្ហាចម្បងដែលយុវជនកំពុងជួបប្រឈមនៅក្នុងសហគមន៍? (អាចគូសយកជម្រើសច្រើនជាងមួយ)**

☐ ក-គ្រឿងញៀន ☐ ខ-ក្មេងទំនើង ☐ គ-ផ្លូវថ្នល់

☐ ឃ-យុវជនបោះបង់ចោលការសិក្សា ☐ ង-ទឹកស្អាតនិងអនាម័យ

☐ ច-អំពើហិង្សាក្នុងគ្រួសារ ☐ ឆ-បញ្ហាយុវជនចំណាកស្រុក

**៥. តើប្អូនគិតថាក្រុមប្រឹក្សាឃុំត្រូវធ្វើអ្វីខ្លះ ដើម្បីជំរុញឱ្យយុវជនចូលរួមបានច្រើនក្នុងដំណើរការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ?**

.............................................................................................................

.............................................................................................................



**ឧទាហរណ៍ទី២៖**កម្រងសំណួរវាយតម្លៃការពេញចិត្តរបស់យុវជនលើសេវាសាធារណៈផ្តល់ដោយក្រុមប្រឹក្សាឃុំ

**១. តើប្អូនធ្លាប់ទៅសាលាឃុំដែរឬទេ?**

☐ ក-ធ្លាប់ ☐ ខ-មិនធ្លាប់

**២. តើប្អូនធ្លាប់ប្រើប្រាស់សេវាសាធារណៈផ្តល់ដោយក្រុមប្រឹក្សាឃុំដែរឬទេ?**

☐ ក-ធ្លាប់ ( ប្រសិនជាធ្លាប់ សូមបន្តទៅសំណួរទី៣ )

☐ ខ-មិនធ្លាប់ ( ប្រសិនជាមិនធ្លាប់ សូមរំលងទៅសំណួរទី៥ )

**៣. តើប្អូនពេញចិត្តចំពោះការផ្តល់សេវាសាធារណៈដោយក្រុមប្រឹក្សាឃុំដែរឬទេ? (អាចគូសយកជម្រើសតែមួយគត់)**

☐ ក-មិនពេញចិត្តសោះ ☐ ខ-ពេញចិត្តតិចតួច ☐ គ-ពេញចិត្តមធ្យម

☐ ឃ-ពេញចិត្តខ្លាំង ☐ ង-ពេញចិត្តទាំងស្រុង

**៤. តើមានចំណុចល្អអ្វីខ្លះចំពោះការផ្តល់សេវាសាធារណៈដោយក្រុមប្រឹក្សាឃុំក្នុងរយៈពេល១ឆ្នាំនេះ?**

.............................................................................................................

.............................................................................................................

**៥. តើមានចំណុចអ្វីខ្លះដែលគួរកែលម្អដើម្បីឱ្យការផ្តល់សេវាសាធារណៈដោយក្រុមប្រឹក្សាឃុំមានភាពប្រសើរឡើង?**

.............................................................................................................

.............................................................................................................

**សម្គាល់៖**ចំពោះកម្រងសំណួរទាក់ទងនឹងសេវាសាធារណៈ ក្រុមប្រឹក្សាឃុំ សង្កាត់អាចជ្រើសរើសសេវាសាធារណៈជាក់លាក់បាន ដូចជាសេវារដ្ឋបាល សេវាសុខភាព សេវាអប់រំ....ដែលផ្តល់ដោយរដ្ឋបាលឃុំ សង្កាត់។

# ឧបសម្ព័ន្ធទី៥៖វេទិកាសំណួរចម្លើយ

ការរៀបចំវេទិកាសំណួរចម្លើយរវាងយុវជននិងក្រុមប្រឹក្សា គឺជាវិធីសាស្ត្រមួយក្នុងការទាក់ទាញចំណាប់អារម្មណ៍របស់យុវជននៅក្នុងការអភិវឌ្ឍមូលដ្ឋាន ក៏ដូចការកសាងទំនុកចិត្តរវាងក្រុមប្រឹក្សានិងយុវជនផងដែរ។ ក្រុមប្រឹក្សាឃុំ សង្កាត់អាចអនុវត្តតាមជំហានខាងក្រោមនៅពេលរៀបចំវេទិកាសំណួរចម្លើយ៖

## ក-មុនពេលរៀបចំវេទិកាសំណួរចម្លើយ

- សម្រេចនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់នូវការរៀបចំវេទិកាសំណួរចម្លើយរវាងយុវជន និងក្រុមប្រឹក្សា
- ចាត់តាំងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាខ្លះដែលនឹងចូលរួម និងឆ្លើយសំណួររបស់យុវជន
- សម្រេចកំណត់ទីកន្លែង កាលបរិច្ឆេទ និងពេលវេលា ដែលត្រូវរៀបចំវេទិកាសំណួរចម្លើយជាមួយនឹងយុវជន ដោយត្រូវពិចារណារកទីកន្លែងដែលអ្នកចូលរួមស្គាល់ និងងាយស្រួលស្វែងរក
- ជ្រើសរើសអ្នកសម្របសម្រួលដែលមានបទពិសោធ
- ផ្សព្វផ្សាយដល់យុវជនទូទៅឱ្យដឹងពីវេទិកា។

## ខ-កំលុងវេទិកាសំណួរចម្លើយ

- អ្នកសម្របសម្រួលចាប់ផ្តើមបើកវេទិកា ដោយប្រាប់ពីគោលបំណង និងដំណើរការវេទិកា
- អ្នកសម្របសម្រួលស្វាគមន៍តំណាងក្រុមប្រឹក្សាឃុំ សង្កាត់ជាផ្លូវការ ហើយបន្ទាប់មកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណែនាំខ្លួនឱ្យយុវជនបានស្គាល់
- យុវជនអាចសួរសំណួរដល់ក្រុមប្រឹក្សាឃុំ សង្កាត់ដោយផ្ទាល់ ឬអាចសរសេរលើក្រដាសក៏បាន
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ពន្យល់និងឆ្លើយសំណួររហូតអស់សំណួរដែលបានសរសេរ
- ប្រសិនបើនៅមានសំណួរបន្ថែម ក្រុមប្រឹក្សាឃុំ សង្កាត់អាចឆ្លើយសំណួរទាំងនោះម្តងមួយៗរហូតចប់កម្មវិធី។

## គ-ក្រោយពេលវេទិកាសំណួរចម្លើយ

- ក្រុមប្រឹក្សាឃុំ សង្កាត់ពិភាក្សាលើចំណុចខ្លាំងនិងចំណុចខ្សោយនៃវេទិកាសំណួរចម្លើយរវាងយុវជន និងក្រុមប្រឹក្សាឃុំ សង្កាត់
- ប្រសិនមានបញ្ហាដែលមិនអាចឆ្លើយបំភ្លឺបាន ទាមទារនូវការពិភាក្សាលម្អិត ឬតម្រូវឱ្យធ្វើសេចក្តីសម្រេចក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយត្រូវយកបញ្ហាទាំងនោះដាក់ក្នុងរបៀបវារៈកិច្ចប្រជុំរបស់ខ្លួន។





# ឧបសម្ព័ន្ធទី៦៖ការពិភាក្សាជាមួយនឹងក្រុមគោលដៅយុវជនជាក់លាក់

ការពិភាក្សាជាមួយនឹងក្រុមគោលដៅយុវជនជាក់លាក់ គឺជាវិធីសាស្ត្រដ៏ល្អសម្រាប់ទទួលបានការចូលរួមមតិ ឬយោបល់របស់យុវជនក្នុងដំណើរការអភិវឌ្ឍមូលដ្ឋាន។ ក្រុមប្រឹក្សាឃុំ សង្កាត់មានឱកាសដឹងអំពីបញ្ហានិងតម្រូវការរបស់យុវជន ដើម្បីជាត្រីវិស័យសម្រាប់រៀបចំផែនការឆ្លើយតបទៅនឹងតម្រូវការរបស់យុវជន ហើយអាចរៀបចំគោលនយោបាយក្នុងផលប្រយោជន៍ដល់ពួកគេ និងរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងគម្រោងថវិកាឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់អាចរៀបចំការពិភាក្សាជាមួយនឹងក្រុមយុវជនជាក់លាក់តាមជំហានសំខាន់ៗដូចខាងក្រោម៖

## ក-មុនពេលរៀបចំការពិភាក្សា

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកំណត់ប្រធានបទសម្រាប់ពិភាក្សាជាមួយនឹងក្រុមគោលដៅជាក់លាក់។ ចំពោះក្រុមយុវជនក៏អាចលើកយកប្រធានបទរបស់ខ្លួនផ្ទាល់បានផងដែរ
- កំណត់ចំនួនអ្នកចូលរួមនៅក្នុងការពិភាក្សាជាមួយនឹងក្រុមគោលដៅជាក់លាក់។ ជាការប្រសើរការពិភាក្សាជាមួយនឹងក្រុមគោលដៅជាក់លាក់ មិនគួរមានចំនួនអ្នកចូលរួមលើសពី១២នាក់ឡើយ
- ក្នុងករណីចាំចាច់ ក្រុមប្រឹក្សាឃុំ សង្កាត់ក៏អាចអញ្ជើញតំណាងមកពីគណៈកម្មការមាតាបិតាសិស្ស គណៈកម្មការវត្ត អង្គការឬសមាគមពាក់ព័ន្ធនឹងកុមារ និងបណ្តាញយុវជន ឱ្យចូលរួមផងដែរ
- ជ្រើសរើសទីកន្លែងងាយស្រួលរក និងពេលវេលាសមស្របសម្រាប់រៀបចំការពិភាក្សាជាមួយនឹងក្រុមគោលដៅជាក់លាក់
- រៀបចំកម្មវិធី ឬរបៀបវារៈដែលអាចដាក់បញ្ចូលនូវចំណុចមួយចំនួនដូចខាងក្រោម៖
  + បង្ហាញគោលបំណង
  + ប្រធានបទពិភាក្សា
  + ការណែនាំឱ្យស្គាល់អ្នកចូលរួម
  + ការបង្ហាញឯកសារដែលពាក់ព័ន្ធនានា
  + ការពិភាក្សាក្រុមតូច
  + សំណួរសំខាន់ៗដែលត្រូវសួរដល់អ្នកចូលរួម
  + ជ្រើសរើសយកអ្នកសម្របសម្រួលដែលមានបទពិសោធ ឬអាចជាតំណាងយុវជនខ្លួនឯងផ្ទាល់ដើម្បីដឹកនាំការពិភាក្សានេះ។

## ខ-កំលុងពេលពិភាក្សាជាមួយនឹងក្រុមគោលដៅ

- ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រាប់ពីគោលបំណង និងបើកការពិភាក្សា
- កិច្ចប្រជុំត្រូវសម្របសម្រួលដោយមនុស្សពេញវ័យ។ អ្នកសម្របសម្រួលសួរសំណួរ ដោយត្រូវប្រើភាសាសាមញ្ញ និងងាយយល់សម្រាប់យុវជន
- គួររៀបចំឱ្យយុវជនអង្គុយជារង្វង់
- អ្នកសម្របសម្រួលកត់ត្រាលទ្ធផលនៃការពិភាក្សា អនុសាសន៍របស់យុវជន និងការសម្រេចរួមគ្នាប្រសិនជាមាន។

## គ-ក្រោយពេលការពិភាក្សាជាមួយនឹងក្រុមយុវជន

- អ្នកសម្របសម្រួលសង្ខេបសំណើរបស់យុវជន ហើយដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់
- ក្រុមប្រឹក្សាឃុំ សង្កាត់ពិភាក្សាសំណើ និងសម្រេចអំពីរបៀបដែលត្រូវចាត់ចែងសំណើទាំងនេះជាបន្តទៀត
- មេឃុំ ចៅសង្កាត់ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចចំពោះសំណើរបស់យុវជន ទៅឱ្យក្រុមយុវជន៕



## ឧបសម្ព័ន្ធទី៧៖ទម្រង់គម្រោងថវិកាសង្ខេបឃុំ សង្កាត់



ទម្រង់គម្រោងថវិកាសង្ខេបឃុំ សង្កាត់ ឆ្នាំ២០......

រដ្ឋបាលឃុំ ឬសង្កាត់...... ក្រុង ស្រុក ឬខណ្ឌ...... រាជធានី ឬខេត្ត......

| បរិយាយគម្រោង ឬ សកម្មភាព | ទឹកប្រាក់ជារៀល | ទីតាំងគម្រោងនៅភូមិ | ចំនួនអ្នកទទួលផល |
|---|---|---|---|
| ចំណូលសរុប | | | |
| ចំណាយសរុប | | | |
| ចំណាយអភិវឌ្ឍន៍សរុប | | | |
| ចំណាយរដ្ឋបាលសរុប | | | |
| ១. ប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ មន្ត្រីភូមិ និងចំណាយរដ្ឋបាល ឃុំសង្កាត់ | | | |
| ២. ចំណាយប្រតិបត្តិការ | | | |
| ៣. ចំណាយមិនបានគ្រោងទុក | | | |

**សម្គាល់៖**ទម្រង់ថវិកានេះដកស្រង់ចេញពីសេចក្តីណែនាំលេខ០២៥ ស.ណ.ន. ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំនិងការអនុម័តថវិការបស់រដ្ឋបាលឃុំ សង្កាត់។

Australian Aid

unicef
for every child